# កិច្ចប្រជុំទ្វេភាគី រវាងថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយ ប្រតិភូអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី ស្តីអំពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិឧស្សាហកម្ម




នៅព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ មានរៀបចំកិច្ចប្រជុំទ្វេភាគី រវាងថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដឹកនាំដោយឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មជាមួយប្រតិភូអង្គភាពកម្មសិទ្ធិបញ្ញា សឹង្ហបុរី ដឹកនាំដោយ លោក **Daren Tang** នាយកប្រតិបត្តិអង្គភាពកម្មសិទ្ធិបញ្ញាសឹង្ហបុរី (IPOS) ស្តីអំពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិឧស្សាហកម្ម រវាងកម្ពុជា និង សឹង្ហបុរី នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។

ក្នុងឱកាសនោះ កិច្ចប្រជុំបានពិភាក្សាអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំជាន់ខ្ពស់លើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិឧស្សាហកម្ម រវាងកម្ពុជា និងសឹង្ហបុរី ដែលបានបញ្ចប់កិច្ចប្រជុំរបស់ខ្លួនពេញមួយថ្ងៃ នៅថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០១៦ កន្លងមក ។



ឆ្លងកាត់កិច្ចប្រជុំផ្លាស់ប្តូរយោបល់ និងកែសម្រួលរួចមក អង្គប្រជុំបានឈានដល់ពិធីចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំជាន់ខ្ពស់លើកទី៣ រវាងឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោក **Daren Tang** នាយកប្រតិបត្តិអង្គភាពកម្មសិទ្ធិបញ្ញាសឹង្ហបុរី ស្តីអំពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិឧស្សាហកម្មដែលខ្លឹមសារនៃឯកសារសំដៅទៅលើការងារទទួលស្គាល់ និងការពារ ផ្នែកប្រកាសនីយបត្រតក្កកម្ម រវាងកម្ពុជា និង សឹង្ហបុរី ។

តាមខ្លឹមសារសំភាសន៍ជាមួយបណ្តាញទូរទស្សន៍ និងសារព័ត៌មានក្នុងស្រុក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថាៈកម្ពុជា និងសឹង្ហបុរី បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាកាលពីឆ្នាំ២០១៥កន្លងទៅ ស្តីពីកិច្ចសហប្រតបត្តិការផ្នែកប្រកាសនីបត្រតក្កកម្មនេះ មានន័យថាៈអ្នកដាក់ពាក្យ ស្នើសុំប្រកាសនីយបត្រតក្កកម្មអាចដាក់ពាក្យ នៅកម្ពុជាក៏បាន និងសឹង្ហបុរីក៏បាន គឺនឹងត្រូវទទួលស្គាល់ទាំងពីរប្រទេស ។ កត្តានេះ ជាការសហការខ្ពីដៃសឹង្ហបុរី ខណៈពេលដែលប្រទេសសឹង្ហបុរី គេមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ក្នុងការពិនិត្យ វាយតម្លៃ លើប្រកាសនីយបត្រតក្កកម្មជូនអតិថិជន ជាក្រុមហ៊ុន រីរោងចក្រ សហគ្រាស ដែលនេះជាការទាញទំនុកចិត្ត ដល់អ្នកវិនិយោគឱ្យមកបណ្តាក់ទុនរកស៊ីនៅកម្ពុជាកាន់តែច្រើនឡើង ។


IPOS
The 3rd High Level Meeting
on Industrial Property Cooperation
Between


IPOS
The 3rd High Level Meeting
on Industrial Property Cooperation
Between




ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់បន្ថែមថា៖ការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា រវាងកម្ពុជា និងសឹង្ហបុរី គឺជាចំណុចចាប់ផ្តើមដំបូងគេ ក្នុងប្រទេសសមាជិកអាស៊ាន ដែលគោលដៅចម្បងយើងនឹងអាចឈានទៅច្របាច់បញ្ចូលគ្នាជាប្រព័ន្ធកម្មសិទ្ធិបញ្ញាអាស៊ានមួយនៅពេលខាងមុខ គឺដាក់ពាក្យនៅប្រទេសណាមួយក៏បាន នឹងត្រូវមានការទទួលស្គាល់ទូទាំងអាស៊ានតែម្តង ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានជម្រាបថា៖យើងក៏បានដំណើរការមួយជំហ៊ានហើយដែរ ជាមួយសហគមន៍អឺរ៉ុប ដែលសង្ឃឹមថា រយៈពេល០៦ ខែ ទៅ០៩ខែ ខាងមុខនឹងមានលទ្ធផលផ្លែផ្កាជាមួយគ្នា ស្របពេលដែលបច្ចុប្បន្នសហគមន៍អឺរ៉ុប មានសមាជិកជាដៃគូរបស់គេចំនួន៤២ ប្រទេស ។

